ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៤នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៤សម្រាប់ឆ្នាំ២០២០ តាមប្រព័ន្ធ Bluejeans ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានសមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង អង្គការ UNAIDS, HP+, RHAC និងសង្គមស៊ីវិលផ្សេងទៀត ចំនួនសរុប៣២នាក់។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីធ្វើបច្ចុប្បន្នភាព បច្ចេកទេស អន្តរវិស័យក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងពិភាក្សាសម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈដូចខាងក្រោម៖

១.មតិស្វាគមន៍ និងគោលបំណងនៃសិក្ខាសាលា

២.ការសិក្សាពីផលប៉ះពាល់នៃកូវីដ-១៩ ទៅសហគមន៍អ្នកផ្ទុកមេរោគអេដស៍ ដែលបង្ហាញដោយ លោក អ៊ឹង ប៉ូលីន ទីប្រឹក្សា UNAIDS។

៣.វឌ្ឍនភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍ សម្រាប់ប្រជាជនគន្លឹះបង្ហាញដោយ លោកស្រី ប្រាជ្ញ ស៊ីណាត

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមតាមប្រព័ន្ធ Bluejeans នាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានកំណត់ ។

**ប្រធានបទទី១៖** ការសិក្សាពីផលប៉ះពាល់ នៃកូវីដ១៩ ទៅក្រុមអ្នកផ្ទុកមេរោគអេដស៍

ការសិក្សានេះ ត្រូវបានធ្វើដោយ UNAIDS មានរយៈពេល ២សប្តាហ៍ ក្នុងអំឡុងខែមេសា ឆ្នាំ ២០២០ តាមរយៈអនឡាញ (Monkey survey) ដោយមានអ្នកចូលរួមចំនួន ១៨០នាក់ (ភេទប្រុស ៤៥% ភេទស្រី ៤៩% មិនបញ្ជាក់ ៦%) នៅតាម ២៣រាជធានី ខេត្ត ក្រុង។ ការសិក្សានេះ ក៏បានបង្ហាញផងដែរពីក្រុមអាយុនៃអ្នកចូលរួមដោយភាគច្រើន មានអាយុចាប់ពី ៣៦ដល់៥៤ឆ្នាំ។ ជាលទ្ធផលបានបង្ហាញថា អ្នកចូលរួមទាំងអស់បានទទួលនូវការថែទាំ និងព្យាបាលរួចហើយ ៨០% ទទួលក្នុងរាជធានី ខេត្ត ដែលខ្លួនស្ថិតនៅ។

ជាលទ្ធផលនៃការសិក្សា៖

- មានប្រមាណ ៦០%នៃអ្នកចូលរួមបានទទួលនូវកម្មវិធីទទួលថ្នាំរយៈពេលយូរ (MMD) រួចហើយ។

• ៥៣% មានការព្រួយបារម្ភខ្លាំងពីបញ្ហាកូវីដ១៩ ទោះបីយ៉ាងដូចនេះក៏ដោយ ៨០% នៅតែចេញទៅទទួលយកថ្នាំប្រឆាំងមេរោគអេដស៍។

• ការសិក្សាក៏បានបង្ហាញពីកង្វល់មួយចំនួនទាក់ទងកូវីដ១៩ ដូចជា៖ កង្វល់ពីសុខភាពផ្ទាល់ខ្លួន (៦៤%) ពីគ្រួសារ (៥៥%)ពីមុខរបរ(១៥%) ការទៅទទួលយកថ្នាំប្រឆាំងមេរោគអេដស៍ ARV (១១%)។

• អ្នកផ្ទុកមេរោគអេដស៍ស្ទើរតែទាំងអស់(៩៦%) ទទួលបានពីព័ត៌មានស្ដីពី ការបង្ការការឆ្លងមេរោគកូវីដ១៩ និងមានប្រមាណ ៥៦% ចង់ដឹងបន្ថែមពីបញ្ហាកូវីដ១៩នេះ។ មានប្រមាណ ២ភាគ៣(២/៣) មានការយល់ដឹង និងលទ្ធភាពក្នុងការបង្ការការឆ្លងកូវីដ១៩ ក្នុងនោះមានសម្ភារប្រើប្រាស់ដូចជា៖ សាប៊ូ (៧១%) ទឹកលាងដៃ (៥៣%) ម៉ាស់ (៤១%)។

• មានលក្ខខណ្ឌមួយចំនួនដែលពិបាកឱ្យពួកគាត់ធ្វើចត្តាឡីស័ក(១៤ថ្ងៃ) ដូចជា៖ ការទៅទទួលយកសេវា(៧២%)ទៅធ្វើការងារ(៣២%) ផ្ដល់ការថែទាំគ្រួសារ ឬមិត្តភ័ក្រ (១៤%)។

• ការសិក្សានេះក៏បានបង្ហាញថា មាន ៤៩% នៃអ្នកផ្ទុកមេរោគអេដស៍ មានប័ណ្ណក្រីក្រ (ID Poor) ឬប័ណ្ណសមធ៌ម(HEF)។

ជាសំណូមពរពីអ្នកចូលរួមការសិក្សា មួយចំនួនដូចជា៖

• ម៉ាស់ ទឹកលាងដៃ ទឹកអាល់កុល ដើម្បីបង្ការការចម្លង
• ចង់បានថ្នាំ ARV រយៈពេលពី ៤ ទៅ ៦ខែ
• ត្រូវការការគាំទ្រផ្នែកផ្លូវចិត្ត

**ប្រធានបទទី ២៖** វឌ្ឍនភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ សម្រាប់ប្រជាជនគន្លឹះ

• RHAC មានសេវាធ្វើការគ្រប់ដណ្ដប់លើ ១៧ រាជធានី ខេត្ត ដោយផ្ដោតលើប្រជាជនគន្លឹះ។ សេវាគ្របដណ្ដប់នៅតាមរាជធានី ខេត្ត មានទៅតាមក្រុមនៃប្រជាជនគន្លឹះ

• តាមរបាយការណ៍ពីការអប់រំពីជំងឺអេដស៍ នៅ១០ខេត្ត ក្រុង បានរកឃើញអ្នកផ្ទុកមេរោគអេដស៍ថ្មីជាមធ្យម ១នាក់ក្នុង១ថ្ងៃ។

• សេវាអំពើហិង្សាទាក់ទងនឹងផ្លូវភេទ មាននៅ៨ រាជធានី/ខេត្ត៖ បានរកឃើញមានហិង្សាទាក់ទងនឹងផ្លូវភេទប្រមាណ ៤០០ករណី។

• សេវាសុខភាពបន្តពូជ៖ បានប្រឹក្សា និងផ្ដល់សេវាសុខភាពបន្តពូជ បានចំនួន ៦៣,១៧៤ ករណី (កម្មករ) ២០,៤២៧ករណី (សិស្ស និស្សិត) និងផ្សេងទៀត។

• ការអប់រំដល់ក្រុមយុវវ័យ មាន ៣ខេត្ត ក្រុង (សៀមរាប កំពត និងភ្នំពេញ)

- សេវាស្វែងរកការគាំទ្រ ដោយប្រើប្រាស់នូវឯកសារ ឬសៀវភៅដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសុខភាពបន្តពូជ ដើម្បីបញ្ជ្រាបដល់សិស្ស និស្សិត។
- ដោយមានសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល ស្តីពីការបិទសេវាកម្សាន្ត ដូច្នេះក្រុមអ្នកអប់រំ មិនអាចជួបក្រុមគោលដៅដោយផ្ទាល់បាន ជាហេតុនាំឱ្យ RHAC ប្តូរយុទ្ធសាស្ត្រពីជួបដោយផ្ទាល់ក្រុមគោលដៅ មកជួបក្រុមគោលដៅតាមរយៈទូរស័ព្ទ និងបណ្តាញព័ត៌មានសង្គម។

**បញ្ហាប្រឈម៖**

-ក្រុមស្ត្រីគ្រឹះស្ថានកម្សាន្ត សប្បាយចល័តពីកន្លែងមួយទៅកន្លែងមួយ

-អតិថិជនវ័យក្មេងដែលទាក់ទងគ្នាតាមប្រព័ន្ធផ្សព្វផ្សាយសង្គម រួមភេទអត់ប្រើស្រោម

-ក្រុមបុរសស្រលាញ់បុរសវ័យក្មេង មានកម្មវិធីបោះជំរុំរួមភេទ(campsex)

**មតិយោបល់៖**

តំណាងក្រសួងធម្មការ និងកិច្ចការសាសនា បានស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រអប់រំប្រគេនព្រះសង្ឃ និងអាចារ្យ ដើម្បីមានសមត្ថភាពជួយផ្តល់ឱវាទអប់រំ ផ្សព្វផ្សាយ រួមចំណែក បង្ការការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ ដល់ពុទ្ធបរិស័ទ ។

**ឯកឧត្តម** អគ្គលេខាធិការប្រធានអង្គប្រជុំ បានសរុបថា នឹងដកស្រង់បទបង្ហាញ ទាំងពីរខាងលើធ្វើការកែសម្រួល និងអនុវត្តជាក់ស្តែងសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានអំពាវនាវស្នើសុំជំនួយពីដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយសូមជួយផ្តល់ ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិ ដើម្បីពង្រឹងសមត្ថភាពតាមរយៈការ បណ្តុះបណ្តាល ចែករំលែកបទពិសោធន៍ ចំណេះដឹងបច្ចេកទេសរវាងផ្នែកពាក់ព័ន្ធឱ្យបានកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។

ថ្ងៃសុក្រទី៧រោច ខែអាសាឍឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**

បានពិនិត្យត្រឹមត្រូវ
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

**ហួត សេរីវុឌ្ឍ**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់
**អគ្គលេខាធិការ**

**ឈឹម យិនដារ៉េត**